ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation
លេខ: ២៧២ MISTI / ២០២០

# ប្រកាស
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ កំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅដូចខាងក្រោម ៖

- រៀបចំបេសកកម្ម និងរចនាសម្ព័ន្ធរបស់នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ
- រៀបចំតួនាទី និងភារកិច្ចរបស់ការិយាល័យនានា នៃនាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)
ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

- ជានាគុណភាព និងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៣.-**

នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយមានមុខងារ និងភារកិច្ចដូចតទៅ៖

- រៀបចំយន្តការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តគោលនយោបាយផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- រៀបចំផែនការសកម្មភាពការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងកំណត់សូចនាករដើម្បីតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តរយៈពេលខ្លី មធ្យម និងវែង
- តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោង ផែនការមេ ផែនការសកម្មភាព កម្មវិធីអភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ចូលរួមរៀបចំការវាយតម្លៃលើបុគ្គល និងស្ថាប័នដែលមានស្នាដៃក្នុងការអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយសម្រាប់បម្រើឱ្យការកែលម្អការប្រតិបត្តិដែលនៅខ្វះខាត និងចូលរួមលើកមតិដោះស្រាយបញ្ហាប្រឈមដើម្បីឱ្យការអនុវត្តមានលក្ខណៈត្រឹមត្រូវ និងអនុលោមតាមការកំណត់ក្នុងគម្រោង ផែនការ និងគោលនយោបាយ
- រៀបចំលទ្ធផលនៃការវាយតម្លៃដោយពិនិត្យសូចនាករជាមូលដ្ឋាន និងទិសដៅដែលអង្គភាព ស្ថាប័នអនុវត្តផ្ទាល់ និងអង្គភាពស្ថាប័នដែលបានចូលរួមអនុវត្ត ដើម្បីលើកយោបល់ជូនថ្នាក់ដឹកនាំ
- សិក្សាស្រាវជ្រាវវិធីសាស្ត្រពាក់ព័ន្ធការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តលើក្របខណ្ឌគោល-នយោបាយ និងផ្នែកដែលពាក់ព័ន្ធនានា ដើម្បីធានាឱ្យបានការអនុវត្តគោលនយោបាយវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព
- ជំរុញការស្រាវជ្រាវលើការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍
- ផ្សព្វផ្សាយពីលទ្ធផលការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃក្នុងការអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- កៀរគរធនធានជាតិ និងអន្តរជាតិដើម្បីគាំទ្រដល់បេសកកម្មរបស់នាយកដ្ឋាន
- បូកសរុបរបាយការណ៍ វាយតម្លៃលទ្ធផលការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលអគ្គនាយក និង/ឬរដ្ឋមន្ត្រីប្រគល់ជូន។

**ប្រការ៤.-**

នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

**ប្រការ៥.-**

នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ មានការិយាល័យក្រោមឱវាទចំនួន ៤ ដូចខាងក្រោម៖

- ការិយាល័យព័ត៌មាន និងកិច្ចការទូទៅ
- ការិយាល័យតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ
- ការិយាល័យសិក្សាស្រាវជ្រាវវិធីសាស្ត្រ
- ការិយាល័យវាយតម្លៃលើបុគ្គល និងស្ថាប័នវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៦.-**

ការិយាល័យជំនាញនីមួយៗដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

**ប្រការ៧.-**

តួនាទី និងភារកិច្ចរបស់ការិយាល័យជំនាញនីមួយៗ មានដូចតទៅ៖

**១- ការិយាល័យព័ត៌មាន និងកិច្ចការទូទៅ**

ក- តួនាទី

ការិយាល័យព័ត៌មាន និងកិច្ចការទូទៅ ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានលើការងារព័ត៌មាន និងកិច្ចការទូទៅរបស់នាយកដ្ឋាន។

ខ- ភារកិច្ច

ការិយាល័យព័ត៌មាន និងកិច្ចការទូទៅ មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រងការងារមន្ត្រីរាជការ ក្នុងនាយកដ្ឋាន បូកសរុប វាយតម្លៃ គុណភាព សមត្ថភាពមន្ត្រីរាជការ
- ចាត់ចែង គ្រប់គ្រងលិខិតស្នាមចេញ ចូល គ្រប់ប្រភេទ និងបែងចែកលិខិតទាំងនោះទៅតាមទម្រង់និងបែបបទរដ្ឋបាល និងតម្កល់ឯកសារទុកក្នុងនាយកដ្ឋាន
- គ្រប់គ្រងសារពើភ័ណ្ឌ ចលនទ្រព្យ និងអចលនទ្រព្យ របស់នាយកដ្ឋាន បណ្ណាល័យរបស់នាយកដ្ឋាន និងបែងចែក ផ្គត់ផ្គង់សម្ភារៈការិយាល័យក្នុងនាយកដ្ឋាន
- សម្របសម្រួលការងារជាមួយការិយាល័យនានាក្នុងនាយកដ្ឋាននិងស្ថាប័នពាក់ព័ន្ធ លើការងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- លើកគម្រោងចំណូល ចំណាយប្រចាំឆ្នាំរបស់នាយកដ្ឋាន
- តាមដាន និងវាយតម្លៃលទ្ធផលការងារដែលអនុវត្តដោយការិយាល័យជំនាញនីមួយៗ ដើម្បីជាសេនាធិការឱ្យនាយកដ្ឋាន
- រៀបចំសម្របសម្រួលសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលផ្សេងៗ របស់នាយកដ្ឋាន
- រៀបចំសម្ភារៈនិងឧបករណ៍សិក្សាសម្រាប់ធ្វើការបណ្តុះបណ្តាល
- កៀរគរធនធានជាតិ និងអន្តរជាតិដើម្បីគាំទ្រដល់បេសកកម្មរបស់នាយកដ្ឋាន
- បូកសរុបរបាយការណ៍របស់នាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

## ២- ការិយាល័យតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ក- តួនាទី

ការិយាល័យតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានលើការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

ខ- ភារកិច្ច

ការិយាល័យតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ មានភារកិច្ចដូចតទៅ៖

- រៀបចំយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- រៀបចំផែនការសកម្មភាពការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងកំណត់សូចនាករដើម្បីតាមដានត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តរយៈពេលខ្លី មធ្យម និងវែង
- តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោង ផែនការមេ ផែនការសកម្មភាព កម្មវិធីអភិវឌ្ឍន៍ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយសម្រាប់បម្រើឱ្យការកែលម្អការប្រតិបត្តិ ដែលនៅខ្វះខាត និងចូលរួមលើកមតិដោះស្រាយបញ្ហាប្រឈមដើម្បីឱ្យការអនុវត្តឱ្យមានលក្ខណៈ ត្រឹមត្រូវ និងអនុលោមតាមការកំណត់ក្នុងគម្រោង ផែនការ និងគោលនយោបាយ
- ចូលរួមរៀបចំនិងសម្របសម្រួលកិច្ចការពាក់ព័ន្ធការងារតាក់តែងក្របខណ្ឌ និងប្រព័ន្ធនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយវិស័យពាក់ព័ន្ធ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- កៀរគរធនធានជាតិ និងអន្តរជាតិដើម្បីគាំទ្រដល់បេសកកម្មរបស់នាយកដ្ឋាន
- បូកសរុបរបាយការណ៍ជូននាយកដ្ឋាន
- ទទួលអនុវត្តការកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន។

## ៣- ការិយាល័យសិក្សាស្រាវជ្រាវវិធីសាស្ត្រ

ក- តួនាទី

ការិយាល័យសិក្សាស្រាវជ្រាវវិធីសាស្ត្រ ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋាន លើការងារសិក្សាស្រាវជ្រាវវិធីសាស្ត្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ខ- ភារកិច្ច

ការិយាល័យសិក្សាស្រាវជ្រាវវិធីសាស្ត្រ មានភារកិច្ចដូចតទៅ៖

- រៀបចំប្រមូលឯកសារនានាដែលពាក់ព័ន្ធដល់គម្រោង ផែនការសកម្មភាពដើម្បីសិក្សាជាមូលដ្ឋាន ក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ឧទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

- រៀបចំសូចនាករគន្លឹះជាមូលដ្ឋានសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ
- សិក្សាស្រាវជ្រាវវិធីសាស្ត្រពាក់ព័ន្ធការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តលើក្របខណ្ឌគោលនយោបាយនិងផ្នែកដែលពាក់ព័ន្ធនានា ដើម្បីធានាឱ្យបានការអនុវត្តគោលនយោបាយវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព
- ជំរុញការស្រាវជ្រាវលើការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ពិនិត្យរបាយការណ៍សមិទ្ធកម្ម និងរបាយការណ៍ហិរញ្ញវត្ថុនៃគម្រោង ផែនការសកម្មភាពដើម្បីធ្វើការត្រួតពិនិត្យការអនុវត្តគម្រោងផែនការដែលពាក់ព័ន្ធវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- កៀរគរធនធានជាតិ និងអន្តរជាតិដើម្បីគាំទ្រដល់បេសកកម្មរបស់នាយកដ្ឋាន
- បូកសរុបរបាយការណ៍ជូននាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន។

## ៤- ការិយាល័យវាយតម្លៃលើបុគ្គល និងស្ថាប័នវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

ក- តួនាទី

ការិយាល័យវាយតម្លៃលើបុគ្គល និងស្ថាប័នវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋាន លើការងារវាយតម្លៃលើបុគ្គល និងស្ថាប័នវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ខ- ភារកិច្ច

ការិយាល័យវាយតម្លៃលើបុគ្គល និងស្ថាប័នវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានភារកិច្ចដូចតទៅ៖

- ចូលរួមរៀបចំការវាយតម្លៃលើបុគ្គល និងស្ថាប័នដែលមានស្នាដៃក្នុងការអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ផ្សព្វផ្សាយពីលទ្ធផលការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃក្នុងការអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- សហការជាមួយស្ថាប័នពាក់ព័ន្ធក្នុងការវាយតម្លៃបុគ្គល និងស្ថាប័នដើម្បីដាក់ជូនក្រុមប្រឹក្សាវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ជាតិ
- បង្កើតលក្ខខណ្ឌដោយកំណត់លក្ខណៈសម្បត្តិលើស្នាដៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- កៀរគរធនធានជាតិ និងអន្តរជាតិដើម្បីគាំទ្រដល់បេសកកម្មរបស់នាយកដ្ឋាន
- បូកសរុបរបាយការណ៍ជូននាយកដ្ឋាន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន។

**ប្រការ៨.-**

ការបែងចែកភារកិច្ចរបស់មន្ត្រីនាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយជាសមត្ថកិច្ចរបស់ប្រធាននាយកដ្ឋាន។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)
ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

**ប្រការ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋានតាមជាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងគ្រប់អង្គភាពក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៧រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែសីហា ឆ្នាំ២០២០

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

***កិត្តិសេដ្ឋាបណ្ឌិត* ចម ប្រសិទ្ធ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ១០
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti[illegible]smcabinet@gmail.com

## អង្គការលេខរបស់នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ

ភ្ជាប់ជាឯកសារឧបសម្ព័ន្ធនៃប្រកាសលេខ ២៣២ MISTI/២០២០ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០២០

**ប្រធាននាយកដ្ឋាន**

**អនុប្រធាននាយកដ្ឋាន**

- ការិយាល័យ ព័ត៌មាន និងកិច្ចការទូទៅ
- ការិយាល័យ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ
- ការិយាល័យ សិក្សាស្រាវជ្រាវវិធីសាស្ត្រ
- ការិយាល័យ វាយតម្លៃលើបុគ្គល និងស្ថាប័នវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍